ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ក្រុមជំនួយការងារសហប្រតិបត្តិការអន្តរជាតិ

លេខ: ………………………………

# របាយការណ៍បូកសរុបប្រចាំខែ កក្កដា ឆ្នាំ២០១៩

## I. អំពីកម្លាំង៖

កម្លាំងសរុប៖ ០៧នាក់ (ស្រី ០២នាក់)

## II. សកម្មភាព និងលទ្ធផលការងារ

- **ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩៖** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានដឹកនាំការប្រជុំផ្ទៃក្នុងស្តីពី៖ វឌ្ឍនភាពការងារក្រុមការងារ ដែលក្នុងនោះបានផ្តោតសំខាន់ទៅលើការងារមួយចំនួនដូចជា៖

 -ការបញ្ចូលសមាសភាពដឹកនាំថ្មី ជាអនុប្រធានក្រុមចំនួន ៣នាក់
 -ការបញ្ចូលមន្ត្រីស្ម័គ្រចិត្ត ២នាក់ដើម្បីជួយការងារមួយចំនួនទាក់ទងរដ្ឋបាល
 -ការរៀបចំរចនាសម្ព័ន្ធក្រុមការងារថ្មី
 -ការរៀបចំលិខិតរដ្ឋបាលតាមស្តង់ដាគម្រូ
 -ពង្រឹងលើការប្រមូលរបាយការណ៍ជាពិសេសក្រុមការងារអន្តរក្រសួង
 -ការពិនិត្យ និងរៀបចំកិច្ចប្រជុំ៣ប្រទេស (ប្រទេសបញ្ជូន) កិច្ចប្រជុំប្រព្រឹត្តទៅនៅបន្ទប់លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ ដែលមានវត្តមានសរុប ០៧នាក់ (ស្រី០២នាក់)។

- **ថ្ងៃទី០១ រហូតដល់ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩៖** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាលស្តីពី៖ "ការធ្វើអាជីវកម្មផ្លូវភេទលើកុមារ" ដែលរៀបចំដោយ ស្ថានទូតអូស្ត្រាលី នៅសណ្ឋាគារសូហ្វីតែលភូកេត្រា ដោយមានការចូលរួមពី មន្ត្រីស្នងការរាជធានី ខេត្តចំនួន១១ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នាយកដ្ឋានប្រឆាំងបច្ចេកវិទ្យា អគ្គលេខាធិការដ្ឋាន គជបជ អយ្យការអមរាជធានីខេត្ត ចំនួន០៥ សរុបមានចំនួន ៤០រូប ស្ត្រី០៧រូប។ វគ្គបណ្តុះបណ្តាល និងផ្តោតលើការកិច្ចសហការដើម្បីសង្គ្រោះ បង្ក្រាប លើករណីអាជីវកម្មផ្លូវភេទលើកុមារ និងលើប្រព័ន្ធបច្ចេកវិទ្យា។

- **ថ្ងៃទី០២ និងទី០៣ ខែកក្កដា ឆ្នាំ២០១៩៖** លោកស្រី វរសេនីយ៍ត្រី ថោង សុវត្ថិ ដោយមានការចាត់តាំង របស់លោកជំទាវរដ្ឋលេខាធិការ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជាប្រធានក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ លោកជំទាវ ឧត្តមសេនីយ៍ឯកវេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអញ្ជើញជាគណៈអធិបតី និងដឹកនាំមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលរួម វគ្គបណ្តុះបណ្តាលរយៈពេល០២ថ្ងៃ ស្តីពី "ការសម្របសម្រួលការផ្តល់ សេវាប្រកបដោយគុណភាពសម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី ដែលទទួលរងអំពើហិង្សា" រៀបចំឡើងដោយអង្គការ

UN Women ដែលមានការចូលរួមពី តំណាងក្រសួងស្ថាប័នជាអ្នកអនុវត្តការងារពាក់ព័ន្ធ និងផ្តល់សេវាចាំបាច់ដល់ជនរងគ្រោះ សរុបប្រមាណ៦៣នាក់ (ស្រី៣៧ នាក់)។

**- ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩៖** លោកវរសេនីយ៍ទោ អ៊ឹង ហាក់លៀង បានចូលរួមកិច្ចប្រជុំ ធ្វើសេចក្តីរាយការណ៍ការងារ និងបញ្ហាប្រឈមនានា នៅបន្ទប់ប្រជុំអគ្គលេខាធិការដ្ឋាន គជបជ ក្រោមអធិបតីភាពលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គជបជ។

**- ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩៖** លោកស្រី វរសេនីយត្រី ថោង សុវត្ថិ បានចូលរួមកិច្ចប្រជុំស្តីពី៖ ការរៀបចំវេទិកាអន្តរសាសនាថ្នាក់ជាតិ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លើកទី៣ ដែលនឹងធ្វើឡើង នៅថ្ងៃ១៤កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែ សីហា ឆ្នាំ២០១៩ ដើម្បីពិនិត្យសម្រេចលើកម្មវិធី និងការរៀបចំកិច្ចការពាក់ព័ន្ធផ្សេងៗ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** ។ អញ្ជើញចូលរួមក្នុងអង្គប្រជុំនេះមាន ឯកឧត្តម សាវ៉ាយ ធុន អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា លោកជំទាវ ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ ឯ.ឧ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប ប្រធានក្រុមជំនួយកិច្ចការ ការពារជនរងគ្រោះ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បព្វជិតជាលេខាធិការដ្ឋានសង្ឃនាយក តំណាងគណៈសង្ឃនាយក នាយករងតំណាងអង្គការកាវីតាសកម្ពុជាតំណាងគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា កាតូលិកកម្ពុជា គ្រិស្ទបរិស័ទ្ធដំណឹងល្អកម្ពុជា វត្តមាននៃអង្គប្រជុំមាន២១នាក់ (ស្រី០៤ នាក់)។

**-ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩៖** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានអញ្ជើញចូលរួមបើកកិច្ចប្រជុំ ថ្នាក់ដឹកនាំនៃសេចក្តីសម្រេច ជាប្រធានក្រុមការងារ និងសមាជិកវេទិកាជាតិអន្តរសាសនាលើកទី៣ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលនឹងធ្វើឡើងនៅថ្ងៃ១៤កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩។ អញ្ជើញចូលរួមក្នុងអង្គប្រជុំនេះមាន ឯកឧត្តម លោកជំទាវជាអគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន រដ្ឋបាលសរុប ប្រធាន អនុប្រធានក្រុមជំនួយកិច្ចការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ វត្តមាននៃអង្គប្រជុំមាន ១២នាក់ ស្រី០១ នាក់។

**-ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩៖** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានដឹកនាំបើកកិច្ចប្រជុំស្តីពី៖ ការត្រៀមរៀបចំទិវាអន្តរសាសនាថ្នាក់ជាតិលើកទី៣ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គជបជ។

**-ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩៖** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាអំពីការកំណត់ទិន្នន័យជាក់លាក់ពាក់ព័ន្ធ នឹងជនរងគ្រោះសម្រាប់របាយការណ៍ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ។ កិច្ចប្រជុំនេះប្រព្រឹត្តឡើងក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និង ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវអគ្គលេខាធិការរង ប្រធាន អនុប្រធាន លេខាធិការដ្ឋាន រដ្ឋបាលសរុប ប្រធាន ក្រុមជំនួយកិច្ចការ ទាំង៦ នៃ គ.ជ.ប.ជ ឯកឧត្តម ហ៊ូ វុឌ្ឍី អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក លោកស្រីតំណាងមកពី ក្រសួង ពាក់ព័ន្ធ មានជាអាទិ៍ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនិតិសម្បទា តំណាងអគ្គនាយកដ្ឋាន អន្តោប្រវេសន៍ តំណាង អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម តំណាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ជាច្រើនរូបទៀត វត្តមាន នៃកិច្ចប្រជុំមាន ១៩នាក់ ស្រី០៥នាក់ ។

**-ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩៖** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ សម្រាប់ការរៀបចំកិច្ចប្រជុំពិភាក្សាលើកទី ២ ស្តីពី "ក្រុមប្រទេសបញ្ជូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា ដើម្បីពិភាក្សា

អំពីបញ្ហារួម និង ដំណោះស្រាយរួម" នៅសាលប្រជុំអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ កិច្ចប្រជុំនេះប្រព្រឹត្តឡើងក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និង ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។** អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវអគ្គលេខាធិការរង ប្រធាន អនុប្រធាន លេខាធិការដ្ឋាន រដ្ឋបាលសរុប ប្រធាន អនុប្រធាន ក្រុមជំនួយកិច្ចការទាំង៦ នៃ គ.ជ.ប.ជ ឯកឧត្តម ហ៊ូ វុឌ្ឍី អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ ឯកឧត្តម លីម ឆាយ អនុរដ្ឋលេខាធិការ ក្រសួង សង្គមកិច្ចអតីត យុវជន និងនីតិសម្បទា លោក លោកស្រីតំណាងមកពី ក្រសួងពាក់ព័ន្ធ មាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងយុត្តិធម៌ តំណាង អគ្គនាយកដ្ឋាន អន្តោប្រវេសន៍ តំណាងអគ្គនាយកដ្ឋានអគ្គសញ្ញាណកម្ម តំណាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ជាច្រើនរូបទៀត វត្តមាននៃកិច្ចប្រជុំមាន ២៧នាក់ ស្រី០៨នាក់។

**-ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩៖** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានធ្វើការជួបពិភាក្សាជាមួយក្រុមការងារការីតាស ស្តីពីៈ កម្មវិធីអន្តរសាសនា ថ្នាក់ជាតិ លើកទី៣ នៅអង្គការការីតាស។

**-ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩៖** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា បានដឹកនាំការប្រជុំផ្ទៃក្នុងស្តីពីវឌ្ឍភាពការងាររបស់ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ដែលក្នុងនោះបានផ្តោតសំខាន់ទៅលើចំនុចមួយចំនួនដូចជា៖

-ការរៀបចំ database របស់អង្គការ

-ត្រៀមកិច្ចប្រជុំជាមួយអង្គការ Winrock និង Chapdai

-ការផ្លាស់ប្តូរ sub domain name

-MOU ជាមួយ Chapdai

-ជំរុញការប្រមូលទិន្នន័យរបស់អង្គការដើម្បីដាក់បញ្ចូលទៅក្នុង database

-ស្នើសុំគោលការណ៍សម្តេចដើម្បីសម្ភោធន៍គម្រោង

**-ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩៖** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា លោកវរសេនីយ៍ទោ អ៊ឹង ហាក់លៀង លោកអនុសេនីយ៍ទោ ធន ដារ៉ារិទ្ធ បានចូលរួមកិច្ចប្រជុំ ក្រុមជំនាញអន្តរក្រសួង ស្ថាប័នទាំង៦ ប្រចាំឆមាសទី១ ឆ្នាំ ២០១៩ នៅទីស្តីការក្រសួងមហាផ្ទៃ អគារ A ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ។** អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន ឯកឧត្តម វង សូត រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនិតិសម្បទា លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឯកឧត្តម លោកជំទាវ ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយក នៃអគ្គនាយកដ្ឋានអគ្គសញ្ញាណកម្ម នាយកទីចាត់ការការងារព្រំដែន នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ លោក លោកស្រី ដែលជាតំណាងមកពីក្រសួង ស្ថាប័ន នៃក្រុមការងារជំនាញទាំង៦ ដែលជាសមាជិកនៃ គ.ជ.ប.ជ និងអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

**-ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩៖** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា និងលោកវរសេនីយ៍ទោ អ៊ឹង ហាក់លៀង បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពីៈ "ការវិភាគមុខងារក្របខណ្ឌនគរបាលជាតិ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ" ក្រោមការដឹកនាំដោយ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប ប្រធានក្រុជំនួយកិច្ចទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ វត្តមាននៃអង្គប្រជុំមាន១២នាក់ ស្រី០២នាក់។

**-ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩៖** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា លោកវរសេនីយ៍ឯក អ៊ុន មាន បាន អញ្ជើញចូលរួមពិភាក្សាជាមួយក្រុមការងារ ការីតាសស្វីស ដើម្បីណែនាំពីការប្រមូលទិន្នន័យអង្គការ។

**-ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩៖** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា លោកវរសេនីយ៍ឯក អ៊ុន មាន និង លោក វរសេនីយ៍ទោ តាវ រិកក្តិ បានអញ្ជើញអមដំណើរ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គជបជ** ចូលរួមក្នុងកម្មវិធីវេទិកា សាធារណៈដែលប្រារព្ធឡើងនៅសង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។

**-ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩៖** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា បានដឹកនាំបើកកិច្ចប្រជុំស្តីពី៖ ការត្រៀម រៀបចំទិវាអន្តរសាសនាថ្នាក់ជាតិលើកទី៣ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គជបជ។

**-ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា លោកវរសេនីយ៍ឯក អ៊ុន មាន និង លោកស្រី វរសេនីយ៍ត្រី ថោង សុវត្ថិ បានអញ្ជើញចូលរួមក្នុងជំនួបរវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស និងតំណាងស្ថានទូតអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា ពិភាក្សា អំពីរបាយការណ៍ប្រឆាំងការជួញដូរមនុស្ស របស់សហរដ្ឋអាមេរិកឆ្នាំ២០១៩ នៅបន្ទប់អគ្គលេខាធិការដ្ឋាន គជបជ។

## III. ទិសដៅអនុវត្តបន្ត

- ធ្វើកំណែទម្រង់មួយចំនួន ដែលមានបញ្ហានៅលើគេហទំព័រ http://ngo.ncct.gov.kh និងបញ្ចូលទិន្នន័យ ដែលទទួលបានពីអង្គការបន្ត
- ធ្វើការទំនាក់ទំនងទៅអង្គការដៃគូអភិវឌ្ឍន៍ ដើម្បីកែតម្រូវព័ត៌មានមួយចំនួនដែលបំពេញមិនទាន់បានត្រឹមត្រូវ។
- ត្រៀមរៀបចំកម្មវិធីសិក្ខាសាលាស្តីពី «ការណែនាំបង្ហាញពីប្រព័ន្ធចងក្រង ទិន្នន័យសេវាកម្មដើម្បីប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ( Introduction to Services, Referrals Database for Counter TIP )»

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៩

**ប្រធាន**

**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

**បានឃើញ និងគោរពជូន**

លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ

មេត្តាពិនិត្យ និងសម្រេចដោយក្តីគោរព។

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

**អគ្គលេខាធិការរង**